**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**

# ដំណឹងជ្រើសរើសបុគ្គលិក (លើកទី៣)

**យោង៖** -ចំណារ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ២០១៧ របស់ឯកឧត្តមសាកលវិទ្យាធិការ នៃ ស.វ.ស ផ្សព្វផ្សាយបន្ត ។

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល គឺជាសាកលវិទ្យាល័យបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលមានវ័យ ចំណាស់ជាងគេបំផុត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលត្រូវការជ្រើសរើសបុគ្គលិក ចំនួន **០១រូប** សម្រាប់បម្រើការងារ**ជាអ្នកសម្របសម្រួលកម្មវិធីសុខភាពសាធារណៈ** នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ដែលត្រូវមានភារកិច្ច និង គុណវុឌ្ឍិ ដូចខាងក្រោម៖

| **ក- ភារកិច្ច៖** | **ខ- គុណវុឌ្ឍិ៖** |
|---|---|
| - បង្កើតផែនការការងារ(Working Plan ) ទំនាក់ទំនងជាមួយសមាគមន៍ មូលដ្ឋាន (បន្ទាប់ពីមានកិច្ចព្រមព្រៀង ជាមួយសមាគមន៍ មូលដ្ឋានណាមួយ)<br>- សហការណ៍ជាមួយ គ្រូបង្រៀន និងធ្វើការទំនាក់ទំនងជាមួយសមាគមន៍មូលដ្ឋាន ក្នុងគោលបំណងជួយឲ្យសកម្មភាពចុះសហគមន៍ របស់និស្សិតបរិញ្ញាបត្រផ្នែកសុខភាពសាធារណៈ ឲ្យប្រព្រឹត្តិទៅដោយរលូន<br>- រៀបចំកាលវិភាគសិក្សា កម្មសិក្សាសហគមន៍របស់និស្សិត<br>- ពង្រឹងទំនាក់ទំនងជាមួយសហគមន៍ មូលដ្ឋាន<br>- ជំនួយការងាររដ្ឋបាល និងសិក្សា<br>- គ្រប់គ្រងឯកសារ លិខិតបទដ្ឋាន និងច្បាប់ផ្សេងៗ<br>- ជួយការងារទំនាក់ទំនងផ្សេងៗទាំងក្នុង និងក្រៅសាកលវិទ្យាល័យ<br>- គោរពតាមការចាត់តាំងរបស់ប្រធាន និង ការចាត់តាំងផ្សេងៗ របស់ ស.វ.ស | - មានសញ្ញាបត្របរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសុខាភិបាល ឬបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសុខភាពសាធារណៈ ត្រូវបានលើកទឹកចិត្ត<br>- មានបទពិសោធន៍ផ្នែករដ្ឋបាល និងអប់រំសិក្សា យ៉ាងតិច ០២ឆ្នាំ<br>- មានបទពិសោពិសោធន៍លើការងារសហគមន៍<br>- មានចំណេះដឹងភាសាអង់គ្លេស និង/ ឬ ភាសាបារាំង (ភ្ជាប់មកជាមួយឯកសារបញ្ជាក់ ឬលទ្ធផលតេស្តភាសា )<br>- មានចំណេះដឹង និង ជំនាញប្រើប្រាស់កម្មវិធី Microsoft Office, Internet and Email<br>- មានការប្រាស័យទាក់ទងល្អ រួសរាយ រាក់ទាក់ ស្លូតបូត សុភាពរាបសារ ស្មោះត្រង់ និង គោរពវិន័យល្អ<br>- មានការទទួលខុសត្រូវក្នុងការងារ និង មានស្មារតីធ្វើការជាក្រុម |

**អត្ថប្រយោជន៍ដែលទទួលបាន៖**

- ប្រាក់ឧបត្ថម្ភក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ភ្ជុំបិណ្ឌ និង ឱកាសទិវានារីអន្តជាតិ (សម្រាប់នារី)
- ប្រាក់លើកទឹកចិត្តប្រចាំឆ្នាំ (ចំពោះបុគ្គលិកដែលបានបម្រើការងារចាប់ពី ០១ឆ្នាំឡើងទៅ)
- ឱកាសក្នុងការបណ្តុះបណ្តាលជំនាញបន្ត។

**ព័ត៌មានលម្អិត៖**

- បើបេក្ខជនមានចំណាប់អារម្មណ៍ **សូមទំនាក់ទំនងជាមួយផ្នែកបុគ្គលិក នៃ ស.វ.ស ដើម្បីបំពេញពាក្យសុំចូលបម្រើការងារ ឬ អាចទាញយកទម្រង់ពាក្យសុំនេះនៅលើវេបសាយ (www.uhs.edu.kh) រួចផ្ញើមកផ្នែកបុគ្គលិក (បន្ទប់ M109) ឲ្យបានមុនថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០១៧ វេលាម៉ោង ១៦:០០ រសៀលជាកំហិត។**
- អាស័យដ្ឋានទំនាក់ទំនង៖ ឡូត៍លេខ៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឬ តាមទូរស័ព្ទលេខ **023 430 559 / 077 456 070 / 070 512953 / 015 575 554** E-Mail: sreysam_hong@uhs.edu.kh , orn_samnang@uhs.edu.kh ។

**បញ្ជាក់៖**

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល រក្សាសិទ្ធិក្នុងការធ្វើបញ្ជីឈ្មោះជ្រើសរើសបេក្ខជន(Short List) និង កំណត់ថ្ងៃខែ សម្ភាសន៍ លើកពេល កែប្រែ និង លុបចោលការជ្រើសរើសក្នុងករណីមានភាពមិនប្រក្រតី។
- បេក្ខនារី ត្រូវបានលើកទឹកចិត្តក្នុងការដាក់ពាក្យ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែ មេសា ឆ្នាំ២០១៧

**សាកលវិទ្យាធិការរង** Sm

Sopheap

**សាស្ត្រាចារ្យជំនួយ.សេង_សុភាព**